**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ**

**លេខ** ០២ សវណន

# សេចក្តីណែនាំ
# ស្តីពី
# ការដាក់ឱ្យអនុវត្តនីតិវិធីនិងទម្រង់បែបបទ ការគ្រប់គ្រងការសម្តែងសិល្បៈទស្សនីយភាព ល្ខោនគ្រប់ទម្រង់

អនុលោមតាមអនុក្រឹត្យលេខ១៨២ អនក្រ.បក ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៩ ស្តីពីមុខងារនិងរចនាសម្ព័ន្ធរដ្ឋបាលក្រុង អនុក្រឹត្យលេខ១៨៣ អនក្រ.បក ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៩ ស្តីពីមុខងារនិងរចនាសម្ព័ន្ធរដ្ឋបាលខណ្ឌនៃរាជធានីភ្នំពេញ និងអនុក្រឹត្យលេខ១៨៤ អនក្រ.បក ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៩ ស្តីពីមុខងារនិងរចនាសម្ព័ន្ធរដ្ឋបាលស្រុកដែលផ្តល់សិទ្ធិឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ ក្នុងការប្រមូលសេវារដ្ឋបាលលើវិស័យវប្បធម៌និងវិចិត្រសិល្បៈប្រកបដោយប្រសិទ្ធភាពខ្ពស់ ក្រសួងវប្បធម៌និងវិចិត្រសិល្បៈសូមធ្វើការណែនាំដូចខាងក្រោម៖

១- បុគ្គល ឬ ក្រុមដែលធ្វើសកម្មភាពស្របច្បាប់ទាក់ទងនឹងការសម្តែងសិល្បៈទស្សនីយភាព ល្ខោនគ្រប់ទម្រង់ក្នុងគោលបំណងធ្វើអាជីវកម្ម ត្រូវស្នើសុំលិខិតអនុញ្ញាតនៅការិយាល័យច្រកចេញចូលតែមួយនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ ដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធនៃសេចក្តីណែនាំនេះ។

២- បុគ្គល ឬ ក្រុមដែលស្នើសុំលិខិតអនុញ្ញាតនៅការិយាល័យច្រកចេញចូលតែមួយនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវភ្ជាប់មកជាមួយនូវលិខិតអនុញ្ញាតទទួលស្គាល់ពីមន្ទីរវប្បធម៌និងវិចិត្រសិល្បៈរាជធានី ខេត្ត ស្របតាមប្រកាសលេខ៨០ ប្រ.ក. ចុះថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០០៥ ស្តីពីការពង្រឹងគុណភាពសិល្បៈមហាជន។

៣- រដ្ឋបាលក្រុង ស្រុក ខណ្ឌ មានសិទ្ធិចេញលិខិតអនុញ្ញាតសម្តែងសិល្បៈទស្សនីយភាព ល្ខោនគ្រប់ទម្រង់តាមរយៈការិយាល័យច្រកចេញចូលតែមួយនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ។

៤- បុគ្គលិកជួរក្រោយការិយាល័យច្រកចេញចូលតែមួយនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវស្នើសុំកិច្ចសហការជាមួយអាជ្ញាធរមានសមត្ថកិច្ច ចុះពិនិត្យដល់ទីតាំងការសម្តែងដើម្បីផ្តល់យោបល់បច្ចេកទេសជូនប្រធានការិយាល័យច្រកចេញចូលតែមួយ មុននឹងដាក់សំណុំបែបបទស្នើសុំការអនុញ្ញាតសម្តែងជូនអភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ ពិនិត្យសម្រេច។

៥- បុគ្គល ឬ ក្រុមត្រូវបង្ហាញលិខិតអនុញ្ញាតជូនអាជ្ញាធរមានសមត្ថកិច្ចគ្រប់លំដាប់ថ្នាក់ ក្នុងករណីតម្រូវឱ្យមានការត្រួតពិនិត្យ។

៦- បុគ្គល ឬ ក្រុមសម្តែងសិល្បៈទស្សនីយភាព ល្ខោនគ្រប់ទម្រង់ត្រូវអនុវត្តឱ្យបានខ្ជាប់ខ្ជួនគ្រប់បទប្បញ្ញត្តិដែលមានចែងក្នុងប្រកាសលេខ១៦១ ប្រ.ក. ចុះថ្ងៃទី១៤ ខែតុលា ឆ្នាំ២០១៦ស្តីពីក្រមសីលធម៌នៃអ្នកសិល្បៈរបស់ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ។ ករណីមានភាពមិនប្រក្រតីកើតឡើងក្នុងអំឡុងពេលសម្តែង អាជ្ញាធរមានសមត្ថកិច្ចមានសិទ្ធិផ្អាកជាបណ្តោះអាសន្ននិងមានសិទ្ធិស្នើសុំទៅអភិបាលក្រុង

ទូរសព្ទ / ទូរសារ: 023 218 148 , E-mail : info@mcfa.gov.kh, www.mcfa.gov.kh, ប្រអប់សំបុត្រ 72
មហាវិថីព្រះនរោត្តម លេខ២២៧ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ

ស្រុក ខណ្ឌ ដើម្បីបញ្ជូនបន្តជាផ្លូវការតាមរយៈប្រធានការិយាល័យច្រកចេញចូលតែមួយនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ។

៧- កម្រៃសេវា រយៈពេលនៃការផ្តល់សេវា និងសុពលភាពនៃលិខិតអនុញ្ញាតសម្តែងសិល្បៈទស្សនីយភាពល្ខោនគ្រប់ទម្រង់ ត្រូវអនុវត្តតាមប្រកាសរួមលេខ៦៥៧ សហវ.ប្រក ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១៦ រវាងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ លើកលែងតែមានការកំណត់ផ្សេងពីនេះ។

៨- រដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវធ្វើរបាយការណ៍ជាទៀងទាត់អំពីការចេញបណ្ណអនុញ្ញាតសម្រាប់ការផ្តល់សេវាសាធារណៈក្នុងវិស័យវប្បធម៌និងវិចិត្រសិល្បៈមករដ្ឋបាលរាជធានី ខេត្ត ដើម្បីធ្វើការបូកសរុបនិងរាយការណ៍ជូនក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ដោយចម្លងជូនក្រសួងមហាផ្ទៃ និង មន្ទីរវប្បធម៌និងវិចិត្រសិល្បៈរាជធានី ខេត្ត តាមគោលការណ៍កំណត់។

ទទួលបានសេចក្តីណែនាំនេះ គ្រប់អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងវប្បធម៌និងវិចិត្រសិល្បៈនិងគ្រប់រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវអនុវត្តសេចក្តីណែនាំនេះឱ្យមានប្រសិទ្ធភាពនិងដោយស្មារតីទទួលខុសត្រូវខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ អង្គារ ១២ រោច ខែ មិគសិរ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ២០២២

**រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ**

បណ្ឌិតសភាចារ្យ **ភឿង សកុណា**

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួង ស្ថាប័នពាក់ព័ន្ធ
- លេខាធិការដ្ឋាន គ.ជ.អ.ប. នៃក្រសួងមហាផ្ទៃ
- រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- មន្ទីរវប្បធម៌និងវិចិត្រសិល្បៈរាជធានី ខេត្ត
- ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធនៃសេចក្តីណែនាំ

# ពាក្យស្នើសុំ
# លិខិតអនុញ្ញាតការសម្តែងសិល្បៈទស្សនីយភាព
# លោនគ្រប់ទម្រង់

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# ពាក្យស្នើសុំ
# ការសម្តែងសិល្បៈទស្សនីយភាព ល្ខោនគ្រប់ទម្រង់

ខ្ញុំបាទ-នាងខ្ញុំ ឈ្មោះ............................. អក្សរឡាតាំង ...............................................
ភេទ...........ថ្ងៃខែឆ្នាំកំណើត........................ សញ្ជាតិ................. អាសយដ្ឋានបច្ចុប្បន្ន ផ្ទះលេខ...........
ផ្លូវ...........ភូមិ...................... ឃុំ/សង្កាត់..............................ក្រុង/ស្រុក/ខណ្ឌ.........................
រាជធានី/ខេត្ត........................ អត្តសញ្ញាណបណ្ណ / លិខិតឆ្លងដែនលេខ ...............................................
លេខទូរសព្ទទំនាក់ទំនង ..............................................................................................................
តួនាទី ( ជាម្ចាស់/តំណាង ) ...............................................................................................។

**សូមគោរពជូន**
**លោក លោកស្រីអភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ**
.........................................................................

**កម្មវត្ថុ** ៖ សំណើសុំការសម្តែងសិល្បៈទស្សនីយភាព ល្ខោនគ្រប់ទម្រង់។

សេចក្តីដូចបានជម្រាបជូនក្នុងកម្មវត្ថុខាងលើ ខ្ញុំបាទ-នាងខ្ញុំសូមគោរពជូន **លោក លោកស្រីអភិបាលក្រុង ស្រុក ខណ្ឌ** មេត្តាជ្រាបថា៖ ក្រុមសម្តែង ........................................................... របស់ខ្ញុំបាទ-នាងខ្ញុំមានបំណងសម្តែងសិល្បៈទស្សនីយភាពល្ខោនចាប់ពីថ្ងៃទី........ ខែ........... ដល់ថ្ងៃទី.............. ខែ.............. ឆ្នាំ............. នៅ................................................................................................ ..........................................................................................................................។

អាស្រ័យដូចបានគោរពជូនខាងលើ សូម **លោក លោកស្រីអភិបាល** មេត្តាពិនិត្យនិងសម្រេច។

*សូមជូនភ្ជាប់មកជាមួយ៖*

| | |
|---|---|
| ១- អត្តសញ្ញាណបណ្ណ ឬ លិខិតឆ្លងដែនរបស់អ្នកស្នើសុំ (ថតចម្លងដោយនីត្យានុកូលកម្ម) | ១ច្បាប់ |
| ២- គំនូសបង្ហាញទីតាំងសម្តែង | ១ច្បាប់ |
| ៣- កិច្ចសន្យា | ១ច្បាប់ |
| ៤- រូបថតបច្ចុប្បន្នទំហំ៤x៦ | ៣សន្លឹក |

សូម **លោក លោកស្រីអភិបាល** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ-នាងខ្ញុំ។

ថ្ងៃ.......................... ខែ.............. ឆ្នាំ.......................... ព.ស. ...........
ថ្ងៃទី.............ខែ................... ឆ្នាំ..............

**ស្នាមមេដៃស្តាំ និង ឈ្មោះអ្នកស្នើសុំ**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# កិច្ចសន្យា
## ការសម្តែងសិល្បៈទស្សនីយភាព ល្ខោនគ្រប់ទម្រង់

ខ្ញុំបាទ-នាងខ្ញុំឈ្មោះ...............................................ជាអក្សរឡាតាំង ........................................................ ភេទ........... ថ្ងៃខែឆ្នាំកំណើត............................. សញ្ជាតិ.................. អាសយដ្ឋានបច្ចុប្បន្ន ផ្ទះលេខ........... ផ្លូវ...... ភូមិ........................ ឃុំ/សង្កាត់.................................... ក្រុង/ស្រុក/ខណ្ឌ ............................ រាជធានី/ខេត្ត ........................... តួនាទី (ម្ចាស់ ឬ អ្នកតំណាង).................................. ទូរសព្ទ ................................ ........................... អ៊ីម៉ែល ឬ វេបសាយ.................................................។

## សូមធ្វើកិច្ចសន្យាដូចខាងក្រោម

១- ជានាគោរពគោលការណ៍និងទម្រង់សិល្បៈរបស់ជាតិ មិនកែច្នៃខុសពីលំនាំដើម

២- ជានារាល់ការសម្តែងគោរពតាមគោលការណ៍ណែនាំរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ និង មន្ទីរវប្បធម៌និងវិចិត្រសិល្បៈរាជធានី ខេត្ត

៣- ជានារាល់ការសម្តែងមិនឱ្យមានការប៉ះពាល់អង្គព្រះមហាក្សត្រ ការរើសអើងជាតិសាសន៍ ភេទ ព័ណ៌សម្បុរ ជំនឿ សាសនា ឬ និន្នាការនយោបាយដែលប្រឆាំងទៅនឹងបូរណភាពទឹកដី ឯករាជ្យជាតិ អធិបតេយ្យជាតិ ឬ សន្តិសុខជាតិ និងមិនធ្វើឱ្យប៉ះពាល់ដល់ទំនៀមទម្លាប់ប្រពៃណីល្អរបស់ជាតិ

៤- ជានាមិនឱ្យហួសម៉ោងកំណត់

៥- ជានាសហការល្អជាមួយអាជ្ញាធរមានសមត្ថកិច្ចគ្រប់លំដាប់ថ្នាក់

៦- ទទួលខុសត្រូវលើសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងបរិស្ថានល្អ

៧- អាជ្ញាធរមានសមត្ថកិច្ចមានសិទ្ធិផ្អាកជាបណ្តោះអាសន្នឬបញ្ឈប់ជាផ្លូវការរាល់ការសម្តែងដែលពិនិត្យឃើញថាមិនបានគោរពតាមកិច្ចសន្យាខាងលើ ឬ ប្រាស់ចាកបទប្បញ្ញត្តិទាំងឡាយដែលមានជាធរមាន។

ករណីមិនអនុវត្តកិច្ចសន្យានេះ ខ្ញុំបាទ-នាងខ្ញុំសូមទទួលទោសតាមច្បាប់របស់រដ្ឋដែលបានកំណត់ជាធរមាន។

ថ្ងៃ............................. ខែ............... ឆ្នាំ.............................ព.ស. ...........

ថ្ងៃទី..............ខែ...................... ឆ្នាំ...............

**ស្នាមមេដៃស្តាំ និង ឈ្មោះអ្នកស្នើសុំ**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# លិខិតបញ្ជាក់ទីតាំង

ឈ្មោះ ........................................... ទីតាំងសម្តែង ...........................................
អាសយដ្ឋាន ផ្ទះលេខ ..........ផ្លូវ ...............ភូមិ ...............ឃុំ/សង្កាត់ .....................ក្រុង/ស្រុក/ខណ្ឌ
.......................... រាជធានី/ខេត្ត ............................ ដូចបានបង្ហាញនៅក្នុងគំនូសបំព្រួញខាងក្រោម៖

<u>គំនូសបំព្រួញបង្ហាញទីតាំង</u>

ថ្ងៃ........................ ខែ.............. ឆ្នាំ........................ព.ស. ..........
ថ្ងៃទី.............ខែ.................. ឆ្នាំ.............
**ស្នាមមេដៃស្តាំ និង ឈ្មោះអ្នកស្នើសុំ**

លេខ: ........................
បានឃើញនិងបញ្ជាក់
គំនូសបំព្រួញទីតាំងនេះពិតជាត្រឹមត្រូវប្រាកដមែន
ថ្ងៃទី.............ខែ.................. ឆ្នាំ.............
ហត្ថលេខាមេឃុំ/ចៅសង្កាត់

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋបាល** ……………………………….
**ការិយាល័យច្រកចេញចូលតែមួយ**
**លេខ** ……………………….

# លិខិតអនុញ្ញាត
## ការសម្តែងសិល្បៈទស្សនីយភាព ល្ខោនគ្រប់ទម្រង់

**យោង ៖** – អនុក្រឹត្យលេខ១៨ អនក្រ.បក ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៧ ស្តីពីការបង្កើតយន្តការច្រកចេញចូលតែមួយសម្រាប់ការផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ
– ប្រកាសរួមលេខ៦៥៧ សហវ.ប្រក រវាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ចុះថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០១៦ ស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ
– សេចក្តីណែនាំលេខ……………ចុះថ្ងៃទី……ខែ……ឆ្នាំ………ស្តីពីស្តីពីការដាក់ឱ្យអនុវត្តនីតិវិធីនិងទម្រង់បែបបទនៃការគ្រប់គ្រងការសម្តែងសិល្បៈទស្សនីយភាព ល្ខោនគ្រប់ទម្រង់

អនុញ្ញាតឱ្យឈ្មោះ…………………………………… ភេទ………… ថ្ងៃខែឆ្នាំកំណើត…………………………… សញ្ជាតិ…………………អាសយដ្ឋានបច្ចុប្បន្ន ផ្ទះលេខ……………… ផ្លូវ…………… ភូមិ………………… ឃុំ/សង្កាត់ ……………………… ក្រុង/ស្រុក/ខណ្ឌ …………………… រាជធានី/ខេត្ត…………………… អត្តសញ្ញាណបណ្ណ/លិខិតឆ្លងដែនលេខ ………………………… ដឹកនាំក្រុមទៅសម្តែងនៅភូមិ……………… ឃុំ/សង្កាត់……………………… ស្រុក/ខណ្ឌ ……………………………… រាជធានី/ខេត្ត………………………។
លិខិតអនុញ្ញាតនេះមានសុពលភាពត្រឹមថ្ងៃទី…………ខែ……………ឆ្នាំ……………។
សាមីខ្លួនត្រូវអនុវត្តឱ្យបានត្រឹមត្រូវតាមបទប្បញ្ញត្តិជាធរមាន។

ថ្ងៃ………………… ខែ…………… ឆ្នាំ…………………… ព.ស. …………
…………………… ថ្ងៃទី………… ខែ…………… ឆ្នាំ…………
**អភិបាល**……………………

ករណីមានភាពមិនប្រក្រតីនៃការបម្រើសេវា សូមមេត្តាទំនាក់ទំនងលេខទូរសព្ទ
- ប្រធានការិយាល័យច្រកចេញចូលតែមួយ ……………………………
- ប្រធានការិយាល័យប្រជាពលរដ្ឋ ……………………………